**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៦ សរណន

# សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងខួបលើកទី៣៤ ទិវាជនពិការអន្តរជាតិ និងខួបលើកទី១៨ ទិវាជនពិការកម្ពុជា ក្រោមប្រធានបទ "ផ្តល់អាទិភាព និងសិទ្ធិអំណាចដល់ជនពិការ ក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព"

## ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៦

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាតែងប្រារព្ធទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ នៅថ្ងៃទី០៣ ខែធ្នូ ដើម្បីរំលឹកដល់ការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលលើវិស័យពិការភាព ជាពិសេសសុខុមាលភាពបងប្អូនជនពិការកម្ពុជា ស្របតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក យុទ្ធសាស្ត្រអ៊ីនឈាន់ "**ធ្វើឲ្យសិទ្ធិក្លាយជាការពិត**" ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨។

ទិវាជនពិការអន្តរជាតិត្រូវបានប្រារព្ធឡើង ដើម្បីរំលឹកអំពីការតស៊ូទាមទារសិទ្ធិចូលរួមក្នុងសង្គមរបស់ជនពិការប្រមាណ ១ប៊ីលាននាក់ ស្មើនឹងចំនួន ១៥% នៃប្រជាជនសរុបនៅក្នុងពិភពលោក ដែលជាជនបាត់បង់កាយសម្បទា កាយវិញ្ញាណ និងសតិបញ្ញា ដែលតែងតែជួបប្រទះឧបសគ្គរាំងក្នុងជីវិត តាំងពីឆ្នាំ១៩៥០ នៅសហរដ្ឋអាមេរិក និងអឺរ៉ុប សំដៅធ្វើការផ្លាស់ប្តូរនូវស្ថានភាពរស់នៅរបស់ពួកគេ និងបង្កើនការយល់ដឹងអំពីបញ្ហាពិការភាព ដោយផ្តោតសំខាន់លើសិទ្ធិជនពិការ ព្រមទាំងការធ្វើសមាហរណកម្មជនពិការទៅក្នុងគ្រប់សកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និង កីឡា។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាប្រារព្ធទិវាជនពិការនេះឡើង ដើម្បីរំលឹកអំពីមហាវិនាសកម្មនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើន ក្នុងនោះរួមមានជនពិការ ស្ត្រីមេម៉ាយ កុមារកំព្រា ព្រមទាំងគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។ ក្រៅពីនោះ ប្រជាជនកម្ពុជាក៏ប្រឈមនឹងភាពរងគ្រោះមួយចំនួនទៀតដែលនាំឲ្យមានពិការភាពដូចជា គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើត ចាស់ជរា ជំងឺ និងមូលហេតុផ្សេងៗទៀត។

ដើម្បីអបអរសាទរទិវាជនពិការកម្ពុជាលើកទី១៨ និងទិវាជនពិការអន្តរជាតិលើកទី៣៤ ឆ្នាំ២០១៦នេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំចាត់តាំងដូចតទៅៈ

១.ទិវាជនពិការកម្ពុជាលើកទី១៨ និងទិវាជនពិការអន្តរជាតិលើកទី៣៤ ត្រូវប្រារព្ធក្រោមប្រធានបទ "**ផ្តល់អាទិភាព និងសិទ្ធិអំណាចដល់ជនពិការក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព**"។

២.ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជន ឱ្យធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូលឱ្យបានយល់ជ្រួតជ្រាបអំពីប្រវត្តិនៃទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ៣ធ្នូ។

៣.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំពិធីមីទិញ ពិធីជួបសំណេះសំណាលជាមួយជនពិការ កម្មវិធីកម្សាន្តសប្បាយរបស់ជនពិការ នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលនៅក្នុងមូលដ្ឋានរៀងៗខ្លួន។

៤.ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា មូលនិធិជនពិការ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធត្រូវសហការរៀបចំពិធីមីទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកម្សាន្តផ្សេងៗសម្រាប់ជនពិការនៅរាជធានីភ្នំពេញ។

៥.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ ឯកជន ត្រូវរៀបចំចងបដា ពាក្យស្លោកដើម្បីអបអរសាទរទិវាជនពិការកម្ពុជាលើកទី១៨ និងទិវាជនពិការអន្តរជាតិលើកទី៣៤ ដែលមានខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- ផ្តល់អាទិភាព និងសិទ្ធិអំណាចដល់ជនពិការក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព
- ផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកដើម្បីឃើញពីធាតុពិតរបស់ជនពិការ
- កាត់បន្ថយភាពក្រីក្ររបស់ជនពិការ តាមរយៈការផ្តល់ឱកាសការងារស្មើគ្នា
- រួមគ្នាអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់អនាគតយើង
- កែសម្រួលនិងរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបរិស្ថានគ្មានពិការភាព
- ជនពិការត្រូវការផ្តល់តម្លៃជាជាងការអាណិត

ទទួលបានសារាចរណែនាំ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានី ខេត្តត្រូវរៀបចំចាត់តាំងអនុវត្តក្នុងស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ